# <u>សន្និសីទជាតិ</u>

## <u>ស្តីពីកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ</u>

**<u>ថ្ងៃ៧ -៨ កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស ២០១៨</u>**
**<u>ត្រូវនឹងថ្ងៃទី២១-២២ ខែកម្ភៈ ឆ្នាំ២០១៨ នៅមជ្ឈមណ្ឌលសន្និបាតកោះពេជ្រ</u>**

សុន្ទរកថារបស់លោក **សឿង សារឿន** ប្រធានអង្គការ

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) និងជាតំណាងអង្គការសង្គមស៊ីវិល

---

**សូមគោរព! សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា បង ប្អូន ជាភ្ញៀវជាតិ និង អន្តរជាតិ និង អង្គសន្និសីទទាំងមូល!**

ក្នុងនាមគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) ដែលជាអង្គការសមាជិកភាពធំជាងគេនៅក្នុងប្រទេសកម្ពុជា ហើយដែលមានអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាលបរទេស ជាង១៧០ ជាសមាជិក ធ្វើការងារជាដៃគូដើម្បីការលើកកំពស់អភិបាលកិច្ចល្អ បរិយាកាសអំណោយផល និងនិរន្តរភាពរបស់អង្គការស៊ីវិលនៅកម្ពុជា និងក្នុងនាមអង្គការសង្គមស៊ីវិលដែលធ្វើការងារលើកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ និងការអនុវត្តក្របខ័ណ្ឌគណនេយ្យភាពសង្គម ខ្ញុំសូមសម្តែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា ជាពិសេសក្រសួងមហាផ្ទៃ និង គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ដែលបានរៀបចំ និងអនុញ្ញាតឲ្យខ្ញុំបាទ និងសហសេវិកពីសង្គមស៊ីវិលបានចូលរួមក្នុង **<u>សន្និសីទជាតិស្តីពីកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ</u>** នាថ្ងៃនេះ។

យោងតាមការអនុញ្ញាតពីឯកឧត្តមប្រធានរៀបចំអង្គសន្និសីទ និងរបៀបវារៈ ខ្ញុំបាទសូមផ្តោតការចូលរួមជាពិសេសទៅលើប្រធានសំខាន់មួយគឺ **ភាពជាដៃគូរបស់អង្គការសង្គមស៊ីវិលជាមួយរាជរដ្ឋាភិបាលក្នុងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ** ហើយដែលខ្ញុំបាទសូមចូលរួមធ្វើការកត់សម្គាល់ ទៅលើចំនុចមួយចំនួនដូចតទៅនេះ ៖

បើទោះបីជាពាក្យ**កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ** សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ទើបត្រូវបានប្រើប្រាស់ជិតមួយទសវត្សរ៍ចុងក្រោយនេះក៏ដោយ ក៏ប៉ុន្តែ សង្គមស៊ី

វិលកម្ពុជាបានចូលរួមចំណែកយ៉ាងសកម្មជាមួយរាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍប្រទេសកម្ពុជាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ តួនាទី សមិទ្ធិផលសំខាន់ៗ និងវឌ្ឍនភាពជាច្រើន ដែលកើតឡើងតាមរយៈ**ភាពជាដៃគូ**រវាងសង្គមស៊ីវិលជាមួយរាជរដ្ឋាភិបាលដោយផ្ទាល់ក្តី និងប្រយោលក្តី មានដូចជា៖ ១) **ការឆ្លើយតបនឹងគ្រោះមហន្តរាយធម្មជាតិ និងជំងឺរាតត្បាតនានា** តាមរយៈការផ្តល់ជំនួយមនុស្សធម៌ យុទ្ធនាការ និងការអប់រំបង្ការ និងការព្យាបាល។ តួយ៉ាងការចូលរួមឆ្លើយតបនឹងគ្រោះទឹកជំនន់ឆ្នាំ២០១១ យ៉ាងមានប្រសិទ្ធភាព, និង ការកាត់បន្ថយការរីករាលដាលមេរោគអេដស៍ ឲ្យនៅក្នុងកម្រិតទាបបំផុត, ២) **ការចូលរួមពង្រឹងគុណភាពសេវានានា** ជាពិសេសសេវាអប់រំ សុខាភិបាល និងអភិវឌ្ឍជនបទរួមទាំងអនាម័យទូទៅ និងគមនាគមន៍ជនបទ, ៣) **ការលើកកំពស់ប្រជាធិបតេយ្យនិងសិទ្ធិមនុស្ស** តាមរយៈការអប់រំផ្សព្វផ្សាយសិទ្ធិជាមូលដ្ឋាន របស់ប្រជាពលរដ្ឋឲ្យបានសកម្ម ដើម្បីចូលរួមចំណែកក្នុងការអនុវត្ត ព្រមទាំងសម្រេចក្របខ័ណ្ឌគណនេយ្យភាពសង្គម, ៤) **ការអភិវឌ្ឍធនធានមនុស្ស**ដល់ប្រជាពលរដ្ឋជាក្រុមគោលដៅផង អាជ្ញាធរ និងមន្ត្រីរដ្ឋាភិបាលផង និង ៥) **ការលើកកម្ពស់ជីវភាពរស់នៅ និងមុខរបរ**, ៦) **ការអភិរក្សធនធានធម្មជាតិ និង** ៧) **ការសន្ទនាលើគោលនយោបាយ** ជាដើម ។ល។

**សម្តេច ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីជាទីគោរព!**

សង្គមស៊ីវិលស្វាគមន៍ និងទទួលស្គាល់ថា **កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ** គឺជាការប្តេជ្ញាចិត្ត និងជាមធ្យោបាយដ៏វិសេសវិសាលសំដៅដល់ការអភិវឌ្ឍប្រជាធិបតេយ្យនៅមូលដ្ឋាន និងជាការឆ្លើយតបប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងនិរន្តរភាពទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។

ក្រៅពីការចូលរួមអនុវត្តដោយផ្ទាល់នូវកិច្ចប្រឹងប្រែងរបស់ខ្លួនដែលពាក់ព័ន្ធនឹងកំណែទម្រង់នេះ អង្គការសង្គមស៊ីវិលក៏បានចូលរួមផ្តល់អនុសាសន៍ទាំងកម្រិតបច្ចេកទេស និងយុទ្ធសាស្ត្រជាបន្តបន្ទាប់នាពេលកន្លងមក ដើម្បីសម្រេចបាននូវបំណងប្រាថ្នាដ៏វិសេសវិសាលនេះ។ ថ្ងៃនេះខ្ញុំបាទក៏សូមធ្វើការកត់សម្គាល់នូវចំណុចមួយចំនួន ដូចខាងក្រោម៖

១. សង្គមស៊ីវិលសូមអបអរសាទរ និងលើកទឹកចិត្តដល់ គ.ជ.អ.ប និងលេខាធិការដ្ឋានរបស់ខ្លួនចំពោះការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុង**ការអនុវត្តអាណត្តិទូទៅ** របស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលអនុញ្ញាតឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិទទួលបាននូវសមត្ថកិច្ច ការទទួលខុសត្រូវ និងការបំពេញកាតព្វកិច្ចរបស់ខ្លួនដើម្បីដោះស្រាយតម្រូវការចាំបាច់នានានៅកម្រិតសហគមន៍។ សូមលើកទឹកចិត្ត គ.ជ.អ.បធ្វើការវាយតម្លៃទៅលើគុណភាពនៃសកម្មភាពរបស់ SNDD ដើម្បីសិក្សា ក៏ដូចជាដើម្បីដោះស្រាយបញ្ហាគម្លាត/បញ្ហាប្រឈម និងរកដំណោះស្រាយសមស្របសម្រាប់រក្សានូវប្រសិទ្ធភាពនៃកំណែទម្រង់នេះ

ដោយសារតែទីប្រឹក្សាដែលត្រូវបានបញ្ចប់ភ្លាមៗនិងការដោះដូរយ៉ាងគំហុកនូវសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ ស្រុក/ក្រុង និងរាជធានីខេត្ត។

២. សង្គមស៊ីវិលសូមជម្រុញ និងលើកទឹកចិត្តដល់រាជរដ្ឋាភិបាល អនុវត្តពេញលេញនូវគោលការណ៍ **សមភាពយេនឌ័រ និងបរិយាបន្នសង្គម** ដែលធានាឲ្យតួអង្គអភិវឌ្ឍ/ភាគីពាក់ព័ន្ធនានា (រដ្ឋ និង មិនមែនរដ្ឋ) រួមទាំងប្រជាពលរដ្ឋ ស្ត្រី និងយុវជន ដើរតួនាទីចម្បងរបស់ខ្លួនក្នុងដំណើរការកំណែទម្រង់នេះ គឺធានាថា **មិនមានអ្នកណាម្នាក់ត្រូវបានបោះបង់ចោល**។ អង្គការសង្គមស៊ីវិលបានសង្កេតឃើញថា ប្រជាពលរដ្ឋមានការយកចិត្តទុកដាក់ខ្ពស់ ហើយក៏មានការព្រួយបារម្ភជាខ្លាំងផងដែរ ចំពោះបរិយាកាសនយោបាយ សេដ្ឋកិច្ច និងសង្គមនាពេលបច្ចុប្បន្ន ជាពិសេសស្ថានភាពបំណុល បញ្ហាដីធ្លី ការបាត់បង់ធនធានធម្មជាតិ និងទីផ្សារការងារជាដើម ដែលធ្វើឲ្យពួកគាត់ កាន់តែមានភាពភាពសកម្មក្នុងការចូលរួមផ្តល់មតិយោបល់ផ្សេងៗ ដើម្បីកែលម្អ គុណភាព និង លទ្ធផលនៃកំណែទម្រង់នេះ។

៣. សង្គមស៊ីវិលស្នើសុំឲ្យរាជរដ្ឋាភិបាល និង គ.ជ.អ.ប ពន្លឿនការអនុវត្ត **អភិក្រមភាព ជាដៃគូពហុភាគី (រដ្ឋាភិបាល សង្គមស៊ីវិល ដៃគូអភិវឌ្ឍ និងវិស័យឯកជន)** តាមរយៈការពង្រឹង និងពង្រីកគុណភាពយន្តការភាពជាដៃគូនានាដូចជាក្រុមការងារបច្ចេកទេស (TWG) ដែលរាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាលជាច្រើន និងដៃគូអភិវឌ្ឍបានចូលរួមកសាង និងអនុវត្តផែនការកំណែទម្រង់។ គណៈកម្មាធិការគ្រប់គ្រង (PSC) និងក្រុមការងារសម្រាប់គ្រប់គ្រងនិងអនុវត្តផែនការគណនេយ្យភាពសង្គម នឹងត្រូវមានការប្តេជ្ញាចិត្តបន្តទៀតក្នុងការកៀរគរធនធានសម្រាប់គាំទ្រការអនុវត្តអភិក្រមថ្មីមួយនេះ។

៤. សង្គមស៊ីវិលសូមលើកទឹកចិត្តដល់រដ្ឋាភិបាលថ្នាក់ជាតិបង្កើនភាពជាម្ចាស់របស់រដ្ឋ (វិធីសាស្ត្រប្រកបដោយចីរភាព) ដើម្បីអនុវត្តកំណែទម្រង់**វិមជ្ឈការ និងវិសហមជ្ឈការ** ជាពិសេសគឺបង្កើនបរិមាណហិរញ្ញប្បទាន ដល់កម្រិតស្រុក/ក្រុង និងឃុំ/សង្កាត់ ដើម្បីឆ្លើយតបទៅនឹងអាទិភាពរបស់ប្រជាពលរដ្ឋឱ្យបានប្រសើរលើសពីការសន្យា។ បង្កើនល្បឿនអនុវត្តការផ្ទេរមុខងារដែលមានអាទិភាព (តាមតម្រូវការ)។ បង្កើនការវិនិយោគរបស់រដ្ឋាភិបាល (ថវិកា) ទៅនឹងការអនុវត្ត គណនេយ្យភាពសង្គមជាបន្តបន្ទាប់ ជាពិសេសបើអាចធ្វើទៅបានគឺទទួលខុសត្រូវទាំងស្រុង (ទាំងផ្នែកតម្រូវការ និងផ្គត់ផ្គង់) នៅឆ្នាំ ២០២១។ ពន្លឿនការអនុវត្តការរៀបចំបែងចែកប្រាក់ចំណូល (ពន្ធនិងមិនមែនពន្ធ) នៅថ្នាក់ស្រុកនិងថ្នាក់ភូមិ ឃុំ។

៥. សង្គមស៊ីវិលស្នើសុំឲ្យដៃគូអភិវឌ្ឍទាំងអស់ បន្តគាំទ្រដល់រដ្ឋាភិបាលកម្ពុជា និងអង្គការសង្គមស៊ីវិលក្នុងការអនុវត្តនូវកំណែទម្រង់ទាំងអស់ពាក់ព័ន្ធទៅនឹងដំណើរការអភិវឌ្ឍតាមបែប ប្រជាធិបតេយ្យ ដែលយើងទាំងអស់គ្នាមានជំនឿយ៉ាងមុតមាំថា កំណែទម្រង់នេះគឺជាមធ្យោបាយដ៏ត្រឹមត្រូវ ជម្រុញឲ្យមានអត្ថប្រយោជន៍យ៉ាងធំធេងជូនដល់ប្រជាពលរដ្ឋកម្ពុជា។

**សម្តេច ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីជាទីស្នេហា!**

ជាថ្មីម្តងទៀត ខ្ញុំសូមបញ្ជាក់ថា សង្គមស៊ីវិលប្តេជ្ញាចិត្តនឹងដើរតួនាទីយ៉ាងសំខាន់ក្នុង**ការពិភាក្សាអំពីគោលនយោបាយជាពិសេស ការផ្ទេរនិងការអនុវត្តមុខងារ** ជាមួយរដ្ឋាភិបាល ចូលរួម**ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស** ចូលរួម**ការពង្រឹងអំណាចដល់ប្រជាពលរដ្ឋ ការអនុវត្តផែនការគណនេយ្យភាពសង្គម** ចូលរួមក្នុង**ការកៀរគរធនធាន** ចូលរួមក្នុងការ**ពង្រឹងភាពជាដៃគូពហុភាគី** និង**ការបំពេញតួនាទីផ្សេងៗ**ជាច្រើនទៀតសម្រាប់គាំទ្រដល់ការ**អភិវឌ្ឍប្រកបដោយប្រជាធិបតេយ្យ និងចីរភាពសម្រាប់ ប្រទេសកម្ពុជា** ដែលទាំងនេះជា**បំណងប្រាថ្នាតែមួយគត់**របស់សង្គមស៊ីវិល។

វត្តមាន និងការចូលរួមរបស់សង្គមស៊ីវិល តែងតែដើរតួនាទីយ៉ាងសំខាន់ ក្នុងការជម្រុញនូវកិច្ចសហប្រតិបត្តិការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ប្រកបដោយប្រសិទ្ធភាព និងចីរភាព។ ដើម្បីធានាការចូលរួមរបស់អង្គការសង្គមស៊ីវិលអោយមានភាពពេញលេញ និងប្រកបទៅដោយគុណភាព យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា សង្គមស៊ីវិលនឹងទទួលបាននូវ**បរិយាកាសអំណោយផល លំហប្រជាធិបតេយ្យ កិច្ចសហប្រតិបត្តិការ** និងមានការអនុវត្តក្របខ័ណ្ឌច្បាប់ ប្រកបដោយគតិយុទ្ធ សុចរិត យុត្តិធម៌ និងមិនលំអៀង។។

មុននឹងបញ្ចប់ ខ្ញុំសូមសម្តែងការកោតសរសើរ និងថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំនិងសហការីទាំងអស់របស់ **គ.ជ.អ.ប** ជាពិសេសឯកឧត្តម **សក់ សេដ្ឋា** ឯកឧត្តម **ងី ច័ន្ទ្រផល** និងឯកឧត្តម **ង៉ាន់ ចំរើន** ក្នុងការលើកកម្ពស់ភាពជាដៃគូប្រកបដោយបរិយាបន្នក្នុងការអភិវឌ្ឍនៅក្នុងដំណើការកំណែទម្រង់នេះ។

ខ្ញុំក៏សូមអរគុណផងដែរចំពោះដៃគូអភិវឌ្ឍទាំងឡាយ ជាពិសេសសហគមន៍អឺរ៉ុប និងរដ្ឋជាសមាជិកមួយចំនួន ទីភ្នាក់ងារផ្តល់ជំនួយអភិវឌ្ឍន៍សហរដ្ឋអាមេរិក រដ្ឋាភិបាល និងប្រជាជនជប៉ុន ធនាគារពិភពលោក ធនាគារអភិវឌ្ឍអាស៊ី អង្គការសហប្រជាជាតិ (ដូចជា UNICEF) អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធទាំងឡាយ ដែលបានកំពុងចូលរួមផ្តល់ការគាំទ្រទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុសម្រាប់កំណែ**ទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ**។

ខ្ញុំមានក្តីរំពឹងទុកយ៉ាងមុតមាំថា យើងទាំងអស់គ្នា (ទាំងរដ្ឋាភិបាល ទាំងសង្គមស៊ីវិល វិស័យឯកជន ប្រជាពលរដ្ឋ និងដៃគូអភិវឌ្ឍ) នឹងកាន់តែមានជំនឿទុកចិត្តចំពោះគ្នា មានសេចក្តីសង្ឃឹម សេចក្តីស្រឡាញ់ និងសាមគ្គីភាពយ៉ាងស្អិតរមួតដើម្បីសម្រេចនូវបំណងប្រាថ្នារួមនេះ ក្នុងការធ្វើឲ្យសម្រេចបានយ៉ាងល្អបំផុតនូវកំណែទម្រង់**វិមជ្ឈការ និងវិសហមជ្ឈការ** និងជាពិសេសគឺដើម្បីជម្រុញឲ្យ**ព្រះរាជាណាចក្រ**

**កម្ពុជាមានការអភិវឌ្ឍប្រកបដោយប្រជាធិបតេយ្យ និងចីរភាពជានិរន្ត** សម្រាប់ជា**មរតកដ៏ថ្លៃថ្លា**ដល់**អ្នកជំនាន់ក្រោយៗ**របស់ពួកយើង។

សូមអរគុណ!